00356291

E5/10/5

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / JUL / 2009
ម៉ោង (Time/Heure): 13:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

**សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ**
**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធួ មណី**

កាលបរិច្ឆេទ: ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សេចក្តីសម្រេចលើឈុតខ្សែភាពយន្តដែលបានដាក់ដោយសហព្រះរាជអាជ្ញា**
**និងលើសាក្សី CP3/3/2 និង CP3/3/3**

**សហព្រះរាជអាជ្ញា**
ជាលាង
Robert PETIT

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY

ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX
Marie-Paule CANIZARES

Original EN: 00353231-00353235

Martine JACQUIN

Philippe CANONNE

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”)

**ក្រោយពីបានទទួល**សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង អនុលោមតាម “សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច” ដែលអង្គបុរេជំនុំជម្រះបានប្រកាសដោយផ្ទាល់មាត់ នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ និងបានដាក់សេចក្តីសម្រេចជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៨ (“សេចក្តីសម្រេច”)[1]។

**ក្រោយពីបានទទួល** សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់ខ្សែភាពយន្តជាភស្តុតាងចំនួនពីរឈុត ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ (“ញត្តិ”) និងចម្លើយតបរបស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩[2]។

**បានឃើញ** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងភាពអាចទទួលយកបាន និងភាពពាក់ព័ន្ធនៃឈុតខ្សែភាពយន្តនេះ ព្រមទាំងសំណើរបស់ក្រុមមេធាវីការពារក្តីសុំឱ្យអ្នកនិពន្ធឈុតខ្សែភាពយន្តនេះមកតទល់គ្នាក្នុងសវនាការ ជាមួយនឹងកុមារដែលនៅរស់រានមានជីវិតក្នុងខ្សែភាពយន្ត[3]។

**រំលឹកឡើងវិញ** អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ ពាក់ព័ន្ធនឹងភាពអាចទទួលយកបាននៃឈុតខ្សែភាពយន្តនេះ ព្រមទាំងសេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ ទាក់ទិននឹងភាពពាក់ព័ន្ធនិងយថាភាពរបស់ឈុតខ្សែភាពយន្តនេះ[4]។

**បានឃើញថែមទៀត** នូវសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៩ សុំកោះហៅសាក្សី CP3/3/2 និង CP3/3/3 ព្រមទាំងការសុំដកនូវសំណើនេះវិញដោយដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ នេះកាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩[5]។

---

[1] “សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច” ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/42)។

[2] “ញត្តិរបស់សហព្រះរាជអាជ្ញាដើម្បីដាក់បន្ថែមនូវភស្តុតាងថ្មី” ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ (ឯកសារ E5/10)។ “ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីទៅនឹងញត្តិដើម្បីដាក់បន្ថែមនូវភស្តុតាងថ្មីរបស់សហព្រះរាជអាជ្ញា” ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ (ឯកសារ E5/10/1)។

[3] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី (T) ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ ៣៧ ដល់ ៤៤ និង ៤៧ ដល់ ៥០ (ភាសាអង់គ្លេស)។

[4] “សេចក្តីសម្រេចទៅលើភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគី” ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E5/10/2)។ “សេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងឈុតខ្សែភាពយន្តចំនួន ២វគ្គដែលបង្ហាញដោយសហព្រះរាជអាជ្ញា” ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E5/10/4)។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T

00356293



**វិលីករទ្បើងវិញ** អំពីសក្ខីកម្មរបស់លោក ឆង ចាន់ផល និងសេចក្តីសន្និដ្ឋានបន្ថែមពាក់ព័ន្ធនឹងឈុតខ្សែភាពយន្ត កាលពីថ្ងៃទី ០២ ខែកក្កដា ឆ្នាំ២០០៩ ព្រមទាំងសេចក្តីប្រកាសរបស់ជនជាប់ចោទពាក់ព័ន្ធនឹងសាក្សីរូបនេះកាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩[6]។

**អនុលោមតាម** វិធាន ៨០ និង ៨៧(៣) នៃវិធានផ្ទៃក្នុង។

**ចេញសេចក្តីសម្រេច** ដូចខាងក្រោម៖

## អង្គហេតុ និង សំអាងហេតុ

### ក. អំពីអង្គហេតុ

១. នៅក្នុងញត្តិរបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើសុំដាក់ធ្វើជាភស្តុតាងនូវឈុតខ្សែភាពយន្តចំនួនពីរវគ្គដែលរដ្ឋាភិបាលវៀតណាមបានប្រគល់ឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)[7]។ យោងតាមការអះអាងរបស់សហព្រះរាជអាជ្ញា ឈុតខ្សែភាពយន្តទាំងនេះមានរូបភាពស្តីពីមន្ទីរស-២១ ដែលត្រូវបានថតទុកភ្លាមៗបន្ទាប់ពីការរកឃើញមន្ទីរនេះ ដោយកងទ័ពវៀតណាម នៅថ្ងៃ ឬជុំថ្ងៃទី១០ ខែមករា ឆ្នាំ ១៩៧៩។ ឈុតភាពយន្តទាំងនេះមានភាពពាក់ព័ន្ធនិងមានតម្លៃជាភស្តុតាង ដោយសារតែវាជាឈុតខ្សែភាពយន្តតែមួយគត់ដែលត្រូវបានទទួលស្គាល់ថាបានថតអំពីមន្ទីរស-២១ ភ្លាមៗបន្ទាប់ពីទីកន្លែងនេះត្រូវបានគេប្រើប្រាស់ធ្វើជាពន្ធនាគារមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[8]។ អត្ថិភាពនៃខ្សែភាពយន្តឯកសារនេះត្រូវបានដឹងជាសាធារណៈ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៨ និងត្រូវបានពិនិត្យមើលនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដោយតំណាងការិយាល័យសហព្រះរាជអាជ្ញាចាប់ពីថ្ងៃទី០៦ ខែមករា ឆ្នាំ២០០៩ ។ ដោយសារតែការវាយតម្លៃបឋមបង្ហាញថា ខ្សែភាពយន្តនេះមានភាពពាក់ព័ន្ធ និងញត្តិត្រូវបានដាក់ជូនចំពេលវេលាដែលសមស្របដំបូងបំផុតនោះ អង្គជំនុំជម្រះបានប្រកាសជាបណ្តោះអាសន្នកាលពីថ្ងៃទី១១

---

[5] "បញ្ជីឈ្មោះសាក្សីបន្ថែម និងឯកសារថ្មី" ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E5/13)។ "(ក្រុម៣) Renonciation à l'audition comme témoins de [CP3/3/2] et [CP3/3/3]" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E5/14)។

[6] T ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ២ ដល់ ២១ និង ២២ ដល់ ៩៨ (ភាសាអង់គ្លេស) និង T ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៣ ដល់ ៥ (ភាសាអង់គ្លេស)។

[7] លេខយោងភស្តុតាង ("ERN") V00271181-V00271181 និង V00271182-V00271182។

[8] "ញត្តិរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់បន្ថែមនូវភស្តុតាងថ្មី" ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ (ឯកសារ E5/10) កថាខណ្ឌ ៤, ៧, ដល់ ១៥។

ខែមីនា ឆ្នាំ២០០៩ ថា ខ្សែភាពយន្តនេះអាចទទួលយកបាន ប៉ុន្តែវាជាកម្មវត្ថុនៃការពិនិត្យឡើងវិញដោយអង្គជំនុំជម្រះលើភាពពាក់ព័ន្ធ និងយថាភាពរបស់វាក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី[9]។

២. នៅក្នុងការជំទាស់ទៅនឹងយថាភាពនៃឈុតខ្សែភាពយន្តនេះ ក្រុមមេធាវីការពារក្តីបានតវ៉ាថាវាជាខ្សែភាពយន្តបែបនយោបាយ និងថាខ្សែភាពយន្តនោះមានរឿងមិនពិត និងមានការបំប្លែងជាច្រើនអន្លើ។ ដូចជាភាពយន្តនេះបានពណ៌នាខុសអំពីទីតាំងខ្លោងទ្វារចូលមន្ទីរ ស-២១ និងចំណុចសម្គាល់ផ្សេងៗទៀតនៃខ្លោងទ្វារនេះ។ ក្រុមមេធាវីការពារក្តីបានអះអាងថាមានសាកសពចំនួនតែបួននាក់ប៉ុណ្ណោះដែលសេសសល់នៅមន្ទីរ ស-២១ នៅពេលដែលពួកអ្នកសួរចម្លើយបានបោះបង់ចោលមន្ទីរឃុំឃាំងនេះកាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ចំណែកឯ ឈុតខ្សែភាពយន្តបង្ហាញឱ្យឃើញថាមានចំនួនសាកសពច្រើនជាងនេះ។ ផ្ទុយ ទៅនឹងអ្វីដែលបានពណ៌នានៅក្នុងវគ្គនៃខ្សែភាពយន្តទាំងនេះ ពុំមានកុមារណាម្នាក់ស្ថិតនៅមន្ទីរ ស-២១ នោះទេ នៅពេលដែលកងទ័ពវៀតណាមបានចូលមកដល់។ ហើយក៏ពុំមានកុមារណាម្នាក់អាចគេចផុតពីសេចក្តីស្លាប់លើសពីពីរបីថ្ងៃបានឡើយ នៅក្នុងស្ថានភាពនោះប្រសិនបើពួកគេពុំមានអ្នកណាជួយទេ។ លើសពីនេះទៀត កុមារដែលសម្តែងនៅក្នុងខ្សែភាពយន្តនោះហាក់ដូចជាមានសុខភាពល្អ ចំណែកឯស្ថានភាពឃុំឃាំងនៅមន្ទីរ ស-២១ វិញ មានការលំបាកខ្លាំងណាស់ រីឯអ្នកជាប់ឃុំវិញត្រូវគេបង្អត់អាហារ។ នៅចុងបញ្ចប់ ខ្សែភាពយន្តនេះមិនបានបង្ហាញពីកំណត់ហេតុពិតស្តីពីមន្ទីរ ស-២១ នោះទេ ដោយសារតែវាខកខានមិនបានបង្ហាញពីអ្នកនៅរស់រានមានជីវិតដែលគេបានឃើញនៅទីនោះបន្ទាប់ពីជនជាប់ចោទបានចាកចេញកាលពីថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩[10]។ ប្រសិនបើឈុតខ្សែភាពយន្តនេះត្រូវបានយកទៅប្រើធ្វើជាភស្តុតាងនោះ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យមានការកោះអញ្ជើញអ្នកថតខ្សែវីដេអូនេះមកផ្តល់សក្ខីកម្ម និងដេញដោលទល់មុខគ្នាជាមួយនឹងកុមារដែលនៅរស់រានមានជីវិត[11]។

## ខ. អំពីសំអាងហេតុ

៣. យោងតាមការលើកឡើងរបស់សហព្រះរាជអាជ្ញា ឈុតទីមួយនៃខ្សែភាពយន្ត រួមមានរូបភាពស្តីពីខ្លោងទ្វារចូលរបស់បរិវេណពហុទីតាំងផ្នែកកណ្តាលនៃមន្ទីរ ស-២១ ឈុតនាកដែលបង្ហាញពីទិដ្ឋភាពរួមនៅ

---

[9] "សេចក្តីសម្រេចទៅលើភាពអាចទទួលយកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគី" ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E5/10/2) ទំព័រ ៥ (សេចក្តីសម្រេច និងការណែនាំ)។ ក្រុមមេធាវីការពារក្តីត្រូវបានណែនាំឱ្យបង្ហាញការប្រឆាំងជំទាស់ទៅនឹងយថាភាពនិងភាពពាក់ព័ន្ធនៃខ្សែភាពយន្តនេះ ត្រឹមថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ (ដូចដើងទំព័រខាងលើ កថាខណ្ឌ ទី១៣ និង ទំព័រ៥ (សេចក្តីសម្រេច និងការណែនាំ)។

[10] "សេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងឈុតខ្សែភាពយន្តដែលបង្ហាញដោយសហព្រះរាជអាជ្ញា" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E5/10/4) កថាខណ្ឌទី៤ និង ទី៥។

[11] ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី (T) ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ទំព័រ ៥០ (ភាសាអង់គ្លេស)។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C

00356295



ផ្នែកខាងក្នុងនៃបរិវេណពហុទីតាំង ឈុតឆាក ដែលបង្ហាញពីប្រភេទផ្សេងៗនៃបន្ទប់ឃុំឃាំង និងគ្រឿងឧបករណ៍ផ្សេងៗសម្រាប់បង្ខាំងអ្នកទោសនៅក្នុងបរិវេណនៃពហុទីតាំងផ្នែកកណ្តាលនៃមន្ទីរ ស-២១ ព្រមទាំងរូបភាពសាកសពគំបុកក្បាលដែលនៅជាប់ច្រវ៉ាក់ភ្ជាប់ទៅនឹងគ្រែ។ វគ្គទីពីរ ហាក់ដូចជាពណ៌នាអំពីកងទ័ពវៀតណាម កំពុងតែយកទារកដែលនៅរស់រានមានជីវិតពីរនាក់ និងកូនក្មេងពីរនាក់ចេញពីបរិវេណពហុទីតាំងផ្នែកកណ្តាលនៃមន្ទីរ ស-២១ ក្នុងពេលភ្លាមៗ បន្ទាប់ពីការរកឃើញមន្ទីរនេះដោយកងទ័ពវៀតណាម[12]។ សហព្រះរាជអាជ្ញាស្នើសុំបង្ហាញឈុតខ្សែភាពយន្តនេះ ទីមួយ ដើម្បីបញ្ជាក់ការពិតដែលស៊ីសង្វាក់គ្នាទៅនឹងការផ្តល់សក្ខីកម្មរបស់សាក្សីនានាដែលថាកូនៗរបស់កម្មាភិបាលដែលត្រូវគេចាប់ខ្លួនក៏ត្រូវបានគេយកទៅដាក់នៅក្នុងមន្ទី ស-២១ ដែរ។ ទីពីរ ទារកដែលគេបានឃើញនៅក្នុងខ្សែភាពយន្តនេះហាក់ដូចជាមានសុខភាពទន់ខ្សោយខ្លាំងណាស់ ដែលជាការគាំទ្រផងដែរដល់ការចោទប្រកាន់ដែលថាលក្ខខណ្ឌនៅមន្ទីរ ស-២១ មានលក្ខណៈអមនុស្សធម៌[13]។

៤. ពាក់ព័ន្ធទៅនឹងវត្តមានរបស់កុមារនៅមន្ទីរ ស-២១ ដែលគេបានលើកឡើងនោះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មរបស់លោក នង ចាន់ផល ដែលគេលើកឡើងថាជាកុមារដែលនៅរស់រានមានជីវិតនៅមន្ទីរ ស-២១ រួចហើយ កាលពីថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩[14]។ នៅ ក្នុងពេលផ្តល់សក្ខីកម្ម លោក នង ចាន់ផល ត្រូវគេបង្ហាញរូបភាពចេញពីវគ្គមួយក្នុងចំណោមខ្សែវីដេអូចំនួនពីរវគ្គ ដែលបានបង្ហាញពីកុមារពីរនាក់កំពុងឈរនៅពីមុខទាហាន។ សាក្សីរូបនេះបានប្រាប់អំពីអត្តសញ្ញាណរបស់ក្មេងប្រុសដែលនៅខាងឆ្វេងរូបនោះថាជារូបគាត់ រីឯក្មេងប្រុសម្នាក់ទៀតគឺជាប្អូនប្រុសរបស់គាត់[15]។ នៅក្នុងសវនាការនៅថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ ជនជាប់ចោទបានទទួលស្គាល់ថា លោក នង ចាន់ផល រួមនិងម្តាយរបស់គាត់ត្រូវបានឃុំឃាំងនៅមន្ទីរ ស-២១[16]។ ក្រុមមេធាវីការពារក្តីក៏បានទទួលស្គាល់យ៉ាងច្បាស់លាស់ដែរថាគោលនយោបាយកម្ទេចខ្មាំងសត្រូវសឹងតែកើតមានជានិច្ចទៅលើក្រុមគ្រួសាររបស់ពួកគេរួមទាំងកូនៗផងដែរ[17]។ បន្ទាប់ពីបានពិចារណាទៅលើសក្ខីកម្មរបស់ លោក នង ចាន់ផល ព្រមទាំងសាក្សីផ្សេងទៀតអង្គហេតុដែលបានឯកភាពគ្នានៅចំពោះមុខអង្គជំនុំជម្រះ ព្រមទាំងការទទួលស្គាល់របស់ជនជាប់ចោទផង

---

[12] ញត្តិ, កថាខណ្ឌទី៨, ១៣ ដល់ ១៤។

[13] ដូចដើងទំព័រខាងលើ កថាខណ្ឌទី៨, ១៣ ដល់ ១៥។

[14] T ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ២២ ដល់ ៩៨ (ភាសាអង់គ្លេស)។

[15] T ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៩២។ ERN V00271181-V00271181 (នៅត្រង់នាទីទី ៧ និង [illegible])។

[16] T ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ ៣ ដល់ ៥។

[17] "គោលជំហររបស់ក្រុមមេធាវីការពារក្តីចំពោះអង្គហេតុនៅក្នុងដីកាដំណោះស្រាយ" ចុះថ្ងៃទី២១ [illegible] ឆ្នាំ២០០៨ (ឯកសារ E5/11/6.1) កថាខណ្ឌទី៨០។

នោះ អង្គជំនុំជម្រះយល់ឃើញថាទោះបីជាមិនចាំបាច់មានឈុតខ្សែភាពយន្តនោះក៏ដោយ ក៏គេអាចសន្និដ្ឋានថាកូនៗរបស់កម្មាភិបាលដែលត្រូវគេចាប់ខ្លួន ក៏ត្រូវបានគេយកទៅដាក់នៅក្នុងមន្ទីរ ស-២១ ដែរ។

៥. ពាក់ព័ន្ធនឹងការរៀបចំផ្នែកទីពីរនៃញត្តិ គ្មានអ្វីត្រូវសង្ស័យទេដែលថា លក្ខខណ្ឌនៅមន្ទីរ ស-២១ មានលក្ខណៈអមនុស្សធម៌នោះ[18]។ ឈុតខ្សែភាពយន្តនេះ ហាក់ដូចជានឹងមានផលប៉ះពាល់ទៅលើសវនាការតិចតួចណាស់ និងថាវាមានខ្លឹមសារដដែលៗទាក់ទងនឹងការបង្កើតអង្គហេតុទាំងនេះ អនុលោមតាមខ្លឹមសារនៃវិធាន ៨៧(៣)(ក)។

៦. ក្រុមមេធាវីការពារក្ដី តវ៉ាអំពីយថាភាពនៃឈុតខ្សែភាពយន្តនេះដោយឈរលើហេតុផលមួយចំនួន[19]។ ដើម្បីគូសបញ្ជាក់អំពីកាលៈទេសៈដែលឈុតខ្សែភាពយន្តនេះបានបង្កើតឡើង និងដើម្បីបំពេញចិត្តរបស់ខ្លួនពាក់ព័ន្ធនឹងការពិត និងភាពដែលអាចជឿជាក់បាននោះ អង្គជំនុំជម្រះនឹងទទួលបន្ទុកស៊ើបអង្កេតបន្ថែមមួយចំនួនរួមទាំងកំណត់អត្តសញ្ញាណ និងកោះអញ្ជើញសាក្សីនានាបន្ថែមទៀត។ ចំណុចនេះទំនងជានឹងនាំឱ្យមានការពន្យារពេលសវនាការជាច្រើនយ៉ាងពិតប្រាកដ។

៧. អង្គជំនុំជម្រះកត់សម្គាល់ឃើញថែមទៀតថា ដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម៣ បន្ទាប់ពីបានផ្ដើមគំនិតស្នើសុំឱ្យកោះអញ្ជើញសាក្សីដែលជាជនជាតិវៀតណាម គឺសាក្សី CP3/3/2 និង CP3/3/3 រួចមកបានដកសំណើសុំនេះវិញកាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩[20]។ សាក្សីដែលត្រូវបានស្នើសុំទាំងនេះ គឺជាអ្នកកាសែតដំបូងគេដែលបានចូលមកមន្ទីរ ស-២១ ក្រោយពេលរបបខ្មែរក្រហមបានដួលរលំ និងអាចជាមនុស្សដែលអាចបញ្ជាក់បានអំពីទិដ្ឋភាព និងស្ថានភាពនៃមន្ទីរ ស-២១ នៅខែមករា ឆ្នាំ១៩៧៩ ដែលគេបានឃើញក្នុងខ្សែភាពយន្ត។ ទោះជាយ៉ាងនេះក្ដី កិច្ចខិតខំប្រឹងប្រែងទំនាក់ទំនងជាមួយសាក្សីទាំងនេះដោយអង្គជំនុំជម្រះពុំទទួលបានជោគជ័យនោះឡើយ។ ដោយហេតុនេះ អង្គជំនុំជម្រះមិនកោះហៅសាក្សីទាំងពីរនេះ។

៨. អង្គជំនុំជម្រះ សូមរំលឹកឡើងវិញអំពីវិធាន ៨៧(៣)(ខ) ដែលអនុញ្ញាតឱ្យខ្លួនធ្វើការបដិសេធការពិនិត្យភស្តុតាងដែលមិនអាចរកបាននៅក្នុងរយៈពេលមួយសមស្រប។ អង្គជំនុំជម្រះពិចារណាឃើញថា ការ

---

[18] "គោលជំហររបស់ក្រុមមេធាវីការពារក្ដីចំពោះអង្គហេតុនៅក្នុងដីកាដំណោះស្រាយ" ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ (ឯកសារ E5/11/6.1) កថាខណ្ឌទី១៣៨ ដល់ ៧១។

[19] "សេចក្ដីសន្និដ្ឋានរបស់សហមេធាវីការពារក្ដីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ពាក់ព័ន្ធនឹងឈុតខ្សែភាពយន្តមន្ទីរ ស-២១ ដែលបង្ហាញដោយសហព្រះរាជអាជ្ញា" ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៩ (ឯកសារ E5/10/4) កថាខណ្ឌទី៤ ដល់ ១៥។

[20] "(ក្រុម៣) Renonciation à l'audition comme témoins de [CP3/3/2] et [CP3/3/3]" ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ (ឯកសារ E5/14)។

00356297



ពិនិត្យមើលអំពីភាពអាចជឿជាក់បាននៃឃ្លុតខ្សែភាពយន្តនេះហាក់ដូចជាមិនអាចធ្វើទៅបាននៅក្នុងរយៈពេលមួយសមស្របនោះទេ បើគិតពីលក្ខខណ្ឌបឋមដើម្បីយកវាមកធ្វើជាភស្តុតាងបាននៅចំពោះមុខអង្គជំនុំជម្រះនោះ។ ជាបច្ច័យ ឃ្លុតនៃខ្សែភាពយន្តនេះត្រូវបដិសេធចោលដោយអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣)(ខ)។

## **សេចក្តីសម្រេច**

**បដិសេធ** ញត្តិរបស់សហព្រះរាជអាជ្ញាសុំបង្ហាញឃ្លុតខ្សែភាពយន្តចំនួនពីរភាគនេះនៅចំពោះមុខអង្គជំនុំជម្រះ។

**បដិសេធផងដែរ** នូវសំណើរបស់ក្រុមមេធាវីការពារក្តីសុំឱ្យមានការដេញដោលទល់មុខគ្នារវាងអ្នកថតខ្សែភាពយន្តនេះជាមួយនឹងកុមារដែលនៅរស់រានមានជីវិត។

**មិន** កោះហៅសាក្សី CP3/3/2 និង CP3/3/3 ដើម្បីមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងកិច្ចដំណើរការនៃសំណុំរឿងក្តីនេះ។ 8/15 NWR

ភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

ACCC TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

និល ណុន